# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ១៧៣៥/០៥ **គ.ជ.ប**

## ជម្រាបជូន

**ឯកឧត្តម កែវ ពុទ្ធរស្មី ប្រធានគណបក្ស ហ៊្វុនស៊ិនប៉ិច**

**កម្មវត្ថុ** : ករណីស្នើសុំឱ្យ គ.ជ.ប ពិនិត្យអំពីអធិគ្យានុកូលភាពនៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨ ។

**យោង** : -មាត្រា ១៦ ថ្មី ២១ ២៤ ១០៩ និងមាត្រា ១១០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ

-បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៨

-លិខិតលេខ ៥១៦ ហសប/០៨ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៨ របស់គណបក្ស ហ៊្វុនស៊ិនប៉ិច ។

តាមកម្មវត្ថុ និង យោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបឯកឧត្តមជ្រាបថា បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៨ (ប.ន.ត.រ) ធ្វើឡើងស្របទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ត.រ) ។ ស្របពេលជាមួយគ្នា ប.ន.ត.រ មុននឹងប្រកាសឱ្យប្រើជាផ្លូវការ គ.ជ.ប បានផ្សព្វផ្សាយ និងចែកជូនគ្រប់ភាគីពាក់ព័ន្ធ ដើម្បីឱ្យផ្តល់ជាអនុសាសន៍មក គ.ជ.ប ។ ទាក់ទងនឹងតួនាទីរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ក្នុងការធ្វើកំណត់ហេតុបូកសរុបលទ្ធផលពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គកប/គករ) ដែលគណបក្ស ហ៊្វុនស៊ិនប៉ិច បានលើកឡើង គ.ជ.ប សូមបញ្ជាក់ដូចខាងក្រោម ៖

១- គ.ជ.ប បានប្រគល់សិទ្ធិដល់ គឃ/សប ក្នុងការអនុវត្តការងាររបស់ខ្លួន ស្របតាមមាត្រា ២៤ នៃ ច.ប.ត.រ ។

២- គឃ/សប ត្រូវប្រមូលកំណត់ហេតុ និងឯកសារទាំងអស់ពីគ្រប់ គកប រួចបញ្ជូនទៅ គខ/កប ស្របតាមមាត្រា ១០៩ នៃ ច.ប.ត.រ ។

៣- ក្នុងការបូកសរុបលទ្ធផលក្នុងខេត្ត ក្រុងរបស់ខ្លួន តាមមាត្រា ១១០ នៃ ច.ប.ត.រ គខ/កប ត្រូវតែងតាំងក្រុម មួយចំនួន ដើម្បីត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ចំណុះខេត្ត ក្រុង ដោយផ្ទៀងផ្ទាត់រវាងកំណត់ហេតុរបស់ គឃ/សប (ទម្រង់បែបបទលេខ ១១០៣ និង ១១០៥) និងកំណត់ហេតុរបស់ គកប/គករ (ទម្រង់បែបបទលេខ ១១០១ ១១០២ និង ១១០៨) ហើយ និងមួយក្រុមផ្សេងទៀត ដើម្បីត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងរបស់ខ្លួន ។ ក្រុមទី ២ អនុវត្តការងាររបស់ខ្លួន បន្ទាប់ពីក្រុមទី ១ បញ្ជាក់ថា លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ពិតជាត្រឹមត្រូវពិតប្រាកដមែន ។

៤- ការប្រគល់សិទ្ធិដល់ គឃ/សប គឺដើម្បីបង្កើនប្រសិទ្ធភាពក្នុងការត្រួតពិនិត្យឱ្យបានត្រឹមត្រូវ និងបង្ហាញពីតម្លាភាពក្នុងការអនុវត្តការងារ ដោយមានការអញ្ជើញឱ្យចូលរួមសង្កេតមើលពីសំណាក់គណបក្សនយោបាយនិងអង្គការមិនមែនរដ្ឋាភិបាលជាតិអន្តរជាតិផងដែរ និងដើម្បីជួយសម្រួលការងារមួយចំនួនទៅ គខ/កប ក្នុងការបូកសរុបលទ្ធផលពីគ្រប់ គកប/គករ ក្នុងខេត្ត ក្រុងរបស់ខ្លួន ។

ទន្ទឹមនឹងនេះ អង្គការដើម្បីសន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) ក៏បានបង្ហាញអំពីគោលការណ៍ស្តីពីតម្លាភាព ដោយបានបញ្ជាក់ថា គោលការណ៍ស្តីពីតម្លាភាពតម្រូវឱ្យមានការអនុវត្តស្របតាមច្បាប់កំណត់ និងតាមវិធានគ្រឹះនៃច្បាប់ដែលបង្កើតឡើងតាមលក្ខណៈទូលំទូលាយ និងបើកចំហរ ។ ដំណើរការតម្លាភាពនេះកម្រិតការកើតមាននូវការលួចបន្លំសន្លឹកឆ្នោតបាន ដូច្នេះហើយទើបរាល់ការរាប់សន្លឹកឆ្នោតត្រូវធ្វើឡើងដោយឱ្យគេឯងបានឃើញនឹងដោយអាចផ្ទៀងផ្ទាត់បាន ចាប់ពីថ្នាក់ការិយាល័យបោះឆ្នោត និងតាមលំដាប់ថ្នាក់នៃការគ្រប់គ្រងការបោះឆ្នោត ហើយចុងក្រោយបង្អស់នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាបតាមការគួរ ។

សូមឯកឧត្តម ទទួលនូវការរាប់អានអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨

**គ.ជ.ប គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការ**

តេព.នីថា